ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងរដ្ឋប្បវេណីលេខៈ ១៣១១
ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣
សាលក្រមរដ្ឋប្បវេណីលេខៈ ០២៣/៣
ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤

**សាលក្រមរដ្ឋប្បវេណី**

**តាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកណ្តាល**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤

**សមាសភាពជំនុំជម្រះ**

លោក [redacted] ចៅក្រមសសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**សមាជើមចោទ÷**

+ឈ្មោះ ធនាគារ [redacted] ម.ក ជាធនាគារដែលបានចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា មានទីតាំងស្ថិតនៅអាគារ ROYAL RAILWAY លេខ១០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានលោក [redacted], លោក [redacted], លោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**ចុងចម្លើយ÷**

+ឈ្មោះ [redacted] ណារ៉ុ ភេទស្រី កើតឆ្នាំ១៩៧៤ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០១០៣៣២៥៣០ (០១) ចុះថ្ងៃ១៤ ខែកក្កដា ឆ្នាំ២០១៥ មានអាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ [redacted] មានលោកស្រី [redacted], លោកស្រី [redacted] អត្តលេខ២៨៦២T និងលោក [redacted] អត្តលេខ២៧៣៨T ជាមេធាវីតំណាងដោយអាណត្តិ។

**អង្គហេតុ និងការអះអាងរបស់គូភាគី**

**១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ÷**

ក.បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ដែលជំពាក់មកឱ្យដើមចោទ (ឥណទានសំរាប់ទិញឬសាងសង់ផ្ទះ) ដូចខាងក្រោម៖

១.ប្រាក់ដើមដែលនៅជំពាក់ចំនួន២៧៥,៩៩៥.១៤ (ម្ភៃប្រាំពីរម៉ឺនប្រាំពាន់ប្រាំបួនរយកៅសិបប្រាំដុល្លារអាមេរិក និងដប់បួនសេន)។



Scanned with CamScanner

២.ការប្រាក់ចំនួន១៧,២២១.១៣ (មួយម៉ឺនប្រាំពីរពាន់ពីររយម្ភៃមួយដុល្លារអាមេរិក និងដប់បីសេន) គិតចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០២៣។

៣.ប្រាក់ពិន័យត្រូវបង់លើចំនួនយឺតយាវហួសកំណត់សងចំនួន១២២.៥៣ (មួយរយម្ភៃពីរដុល្លារអាមេរិក និងហាសិបបីសេន)។

៤.កម្រៃផ្សេងៗត្រូវបង់ចំនួន៨,៨២៦.៨៥ (ប្រាំបីពាន់ប្រាំបីរយម្ភៃប្រាំមួយដុល្លារអាមេរិក និងប៉ែតសិបប្រាំសេន)។

៥.ការប្រាក់ចំនួន៧.៥% (ប្រាំពីរក្បៀសហាសិបភាគរយ) ក្នុង១ឆ្នាំ លើប្រាក់ដើមដែលនៅជំពាក់ គិតពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួន។

៦.ការប្រាក់ហួសកំរិតចំនួន២៧.៥០% (ម្ភៃប្រាំពីរក្បៀសហាសិបភាគរយ) ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលប្រើហួសកំរិត គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួន។

៧.ការប្រាក់ពិន័យចំនួន២៧.៥០% (ម្ភៃប្រាំពីរក្បៀសហាសិបភាគរយ) ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលមិនទាន់បានបង់តាមកាលកំណត់ គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០២៣ រហូតដល់សងប្រាក់គ្រប់ចំនួន។

ខ.បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ដែលជំពាក់មកឲ្យដើមចោទ (ឥណទានសម្រាប់ប្រើប្រាស់ក្នុងផ្ទះ) ដូចខាងក្រោម៖

១.ប្រាក់ដើមដែលនៅជំពាក់ចំនួន៥៣,៦៨៦.៧៥ (ប្រាំម៉ឺនបីពាន់ប្រាំមួយរយប៉ែតសិបប្រាំមួយដុល្លារអាមេរិក និងចិតសិបប្រាំសេន)។

២.ការប្រាក់ចំនួន៣២៥.៣៣ (បីរយសែសិបប្រាំបួនដុល្លារអាមេរិក និងសាមសិបបីសេន) គិតចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣។

៣.ការប្រាក់ចំនួន៧.៥០% (ប្រាំពីរក្បៀសហាសិបភាគរយ) ក្នុង១ (មួយ) ឆ្នាំ លើប្រាក់ដើមដែលនៅជំពាក់ គិតពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួន។

៤.ការប្រាក់ហួសកំរិតចំនួន២៧.៥០% (ម្ភៃប្រាំពីរក្បៀសហាសិបភាគរយ) ក្នុងមួយឆ្នាំ លើចំនួនទឹក ប្រាក់ដែលប្រើហួសកំរិត គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួន។



Scanned with CamScanner

ឃ.ការប្រាក់ពិន័យចំនួន២៧.៥០% (ម្ភៃប្រាំពីរក្បៀសហាសិបភាគរយ) លើចំនួនទឹកប្រាក់ដែលមិនទាន់បានបង់តាមកាលកំណត់ គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួន។

គ.បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ (ហ៊ីប៉ូតែក) របស់ដើមចោទចំពោះអចលនវត្ថុដែលជាកម្មសិទ្ធិរបស់ចុងចម្លើយលើប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០០៧០៤៩ ចុះថ្ងៃទី២៤.១២.១៩៩៧ ចេញដោយប្រធាននាយកដ្ឋានសុរិយោដី ខេត្តកណ្ដាល និងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១៦០១០៤០១-០២៣៥ ចុះថ្ងៃទី២៧.០២.២០០៧ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ។

ឃ.បង្គាប់ឱ្យចុងចម្លើយសងសេវាកម្មផ្លូវច្បាប់សម្រាប់មេធាវីចំនួន២០,០០០(ពីរម៉ឺនដុល្លារអាមេរិក)។

ង.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

ច.ប្រកាសសាលក្រមអាចអនុវត្តជាបណ្ដោះអាសន្នបានត្រង់ចំណុច ក.១ និង ខ.១។

**២. អង្គហេតុដែលភាគីអះអាង និងចំណុចវិវាទ**

២.១.រឿងក្ដីនេះ លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ថា៖ នៅក្នុងរឿងនេះ ខ្ញុំបាទសូមរក្សាខ្លឹមសារនៃការទាមទារដូចមាននៅក្នុងពាក្យបណ្ដឹង ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ និងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ ទុកជាបានការដដែល។ ចំពោះអង្គហេតុនៃការទាមទារនេះ និងភស្តុតាងផ្សេងៗគឺខ្ញុំបាទបានដាក់ជូនតុលាការពិនិត្យរួចរាល់អស់ដែរ។ ម្យ៉ាងវិញទៀត ចំពោះអង្គហេតុនៃការទាមទារនេះ គឺភាគីចុងចម្លើយក៏បានទទួលស្គាល់ដែរ។ ហេតុនេះ ខ្ញុំបាទសំណូមពរអោយតុលាការសម្រេចតាមការស្នើសុំរបស់កូនក្ដីខ្ញុំបាទដូចមាននៅក្នុងពាក្យបណ្ដឹង ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ទាំងស្រុង។

២.២.រឿងក្ដីនេះ លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយបានធ្វើសេចក្ដីថ្លែងការណ៍ថា៖ នៅក្នុងរឿងនេះ យើងខ្ញុំនៅតែទទួលស្គាល់អង្គហេតុដែលប្ដឹងមកកូនក្ដីនាងខ្ញុំ ដូចកាលពីនៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ ដដែល ហើយកូនក្ដីយើងខ្ញុំក៏នៅតែរក្សាគោលជំហរក្នុងការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាដដែល។ ប៉ុន្តែដោយសារតែស្ថានភាពសេដ្ឋកិច្ចធ្លាក់ដល់ចំណុចសូន្យដោយសារតែជំងឺកូវីដ១៩ ធ្វើឲ្យកូនក្ដីខ្ញុំមិនអាចរកចំណូលបាន ព្រោះ

កូនក្តីខ្ញុំធ្វើការនៅក្នុងក្រុមហ៊ុនទេសចរណ៍។ ម្យ៉ាងវិញទៀត កូនក្តីខ្ញុំក៏ធ្លាប់មានចំណូលពីការជួលផ្ទះផងដែរ ប៉ុន្តែក៏គ្មានអ្នកជួលទៀតដែរ។ មិនតែប៉ុណ្ណោះ កូនក្តីខ្ញុំក៏បានខិតខំបើកភោជនីយដ្ឋានដើម្បីជួយដល់ស្ត្រីដែលធ្វើសិប្បកម្មខ្មែរ ក៏មិនដំណើរការល្អដូចការរំពឹងទុកដែរជាហេតុធ្វើអោយកូនក្តីខ្ញុំមិនមានលទ្ធភាពគ្រប់គ្រាន់ឡើយ។ ទោះជាយ៉ាងនេះក្តីក៏កូនក្តីយើងខ្ញុំនៅតែមានឆន្ទៈបង់សងធនាគារតាមលទ្ធភាពរបស់គាត់ ដែលមានចំនួន៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក ក្នុងមួយខែ លើកម្ដងទាំង២ (ពីរ)។ ចំពោះការទាមទារផ្សេងទៀត គឺសូមឲ្យតុលាការធ្វើការច្រានចោល។

២.៣.អង្គហេតុដែលគ្មានវិវាទ

ចុងចម្លើយឈ្មោះ [redacted] ណារុំ បានព្រមព្រៀងខ្ចីប្រាក់ពី ធនាគារ ជេត្រាស់ រ៉ូយ៉ាល់ ម.ក ឥណទានសំរាប់ទិញ ឬសាងសង់ផ្ទះចំនួន៣០០,០០០ (សាមសិបម៉ឺនដុល្លារអាមេរិក) សម្រាប់រយៈពេល២៣០ខែ ក្នុងអត្រាការប្រាក់ចំនួន៧.៥% (ប្រាំពីរក្បៀសប្រាំភាគរយ) ក្នុង១ឆ្នាំ និងប្រាក់ពិន័យចំនួន២០% (ម្ភៃភាគរយ) ក្នុង១ឆ្នាំ និងឥណទានសម្រាប់ប្រើប្រាស់ក្នុងផ្ទះចំនួន៦០,០០០ (ប្រាំមួយម៉ឺនដុល្លារអាមេរិក) សម្រាប់រយៈពេល២៣០ខែ ក្នុងអត្រាការប្រាក់ចំនួន៧.៥% (ប្រាំពីរក្បៀសប្រាំភាគរយ) ក្នុង ១ឆ្នាំ និងប្រាក់ពិន័យចំនួន២០% (ម្ភៃភាគរយ) ក្នុង១ឆ្នាំ ដោយបានចុះលិខិតផ្តល់ឥណទាន ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ដោយបានធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយចុងចម្លើយ។ ម្យ៉ាងវិញទៀត ចុងចម្លើយបានព្រមព្រៀងបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុចំនួន២ (ពីរ) កន្លែង គឺ៖ ទី១. ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ០០៧០៤៩ ចុះថ្ងៃទី២៤.១២.១៩៩៧ ចេញដោយប្រធាននាយកដ្ឋានសុរិយោដី ខេត្តកណ្តាល និង ២.វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០១០៤០១-០២៣៥ ចុះថ្ងៃទី២៧.០២.២០០៧ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ដោយបានធ្វើឡើងជាលិខិតយថាភូត និងបានចុះបញ្ជីតាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកជាមួយពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ និងកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ ជាមួយពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ជាមួយធនាគារ ជេត្រាស់ រ៉ូយ៉ាល់ ម.ក ដើម្បីជាការធានាបំណុល។



Scanned with CamScanner

២.៤. ចំណុចវិវាទ

តើការទាមទាររបស់ដើមចោទដែលមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០២៣ មានភាពត្រឹមត្រូវ និងមានមូលដ្ឋានដែលអាចអោយតុលាការសម្រេចតាមការស្នើសុំបានដែរឬទេ?

**៣. ការពិនិត្យភស្តុតាង**

៣.១. ភស្តុតាងដែលស្នើសុំឱ្យពិនិត្យដោយដើមចោទ៖

-លិខិតផ្តល់ឥណទានជូនចំពោះលោកស្រី [redacted] ណារុំ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០១៩។

-ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ណារុំ។

-ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ណារុំ។

-កិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី០៩ ខែតុលា ឆ្នា២០១៩។

-ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០០៧០៤៩ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៧ ចេញដោយប្រធាននាយកដ្ឋានសុរិយោដី។

-វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១២០១០៤០១-០២៣៥ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៧ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល។

-លិខិតលេខRLO/FC/23/0215-Jtrustroyal ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣។

-លិខិតលេខRLO/FC/23/0421-Jtrustroyal ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣។

-លិខិតលេខ២៤៥/HBS/២៣ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣។

-របាយការណ៍បំណុលរបស់លោកស្រី [redacted] ណារុំ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣។

៣.២. ភស្តុតាងដែលស្នើសុំឱ្យពិនិត្យដោយចុងចម្លើយគ្មាន។

**សំអាងហេតុ**

១. ការវិនិច្ឆ័យអំពីចំណុចវិវាទ

យោងតាមការទាមទាររបស់ដើមចោទដែលមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ឃើញថា ការទាមទារនេះមានភាពត្រឹមត្រូវស្របតាមមាត្រា៥៧៨, ៥៨៣ នៃក្រមរដ្ឋប្បវេណី។ ដូច្នេះ គប្បីតុលាការពិចារណាសម្រេចតាមការទាមទាររបស់ដើមចោទ។



Scanned with CamScanner

២. ការវិនិច្ឆ័យអំពីការទាមទារ

យល់ឃើញថា ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ និងលិខិតផ្តល់ឥណទាន ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ រវាងភាគីដើមចោទ និងចុងចម្លើយ អាចបញ្ជាក់បានថា ភាគីចុងចម្លើយពិតជាបានចុះកិច្ចព្រមព្រៀងខ្ចីប្រាក់ពីធនាគារ [redacted] ម.ក លើឥណទានសម្រាប់ទិញ និងសាងសង់ផ្ទះជាទឹកប្រាក់ចំនួន៣០០,០០០ (សាមសិបម៉ឺន) ដុល្លារអាមេរិក និងឥណទានសម្រាប់ប្រើប្រាស់ក្នុងផ្ទះជាទឹកប្រាក់ចំនួន៦០,០០០ (ប្រាំមួយម៉ឺន) ដុល្លារអាមេរិក ប្រាកដមែន។ ហេតុនេះ ការដែលភាគីដើមចោទទាមទារប្រាក់ដើមចំនួន២៧៥,៩៩៥.១២ (ម្ភៃប្រាំពីរម៉ឺនប្រាំពាន់ប្រាំបួនរយកៅសិបប្រាំដុល្លារអាមេរិក និងដប់បួនសេន) លើឥណទានសម្រាប់ទិញ និងសាងសង់ផ្ទះ និងប្រាក់ដើមចំនួន៥៣,៦៨៦.៧៥ (ប្រាំម៉ឺនបីពាន់ប្រាំមួយរយប៉ែតសិបប្រាំមួយដុល្លារអាមេរិក និងចិតសិបប្រាំសេន) លើឥណទានសម្រាប់ប្រើប្រាស់ក្នុងផ្ទះពីភាគីចុងចម្លើយ ឃើញថា មានភាពត្រឹមត្រូវ ស្របតាមបញ្ញត្តិមាត្រា៥៧៨, ៥៧៩ នៃក្រមរដ្ឋប្បវេណី ។ ហេតុដូច្នេះ គប្បីឱ្យតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

យល់ឃើញថា ដើមចោទទាមទារមកតុលាការឱ្យបង្គាប់ឱ្យចុងចម្លើយបង់សងការប្រាក់ចំនួន១៧,២២១.១៣ (មួយម៉ឺនប្រាំពីរពាន់ពីររយម្ភៃមួយដុល្លារអាមេរិក និងដប់បីសេន) គិតចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ និងការប្រាក់ចំនួន៧.៥% (ប្រាំពីរក្បៀសប្រាំភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងប្រាក់គ្រប់ចំនួន ចំពោះឥណទានសម្រាប់ទិញ និងសាងសង់ផ្ទះ។ ឃើញថា ការដែលដើមចោទទាមទារនេះ គឺស្របតាមឆន្ទៈរបស់ចុងចម្លើយដែលមាននៅក្នុងលិខិតផ្តល់ឥណទានជូនចំពោះលោកស្រី [redacted] ណារុំ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ និងកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី០៩ ខែតុលា ឆ្នា២០១៩ ដែលធ្វើឡើងរវាងដើមចោទ និងចុងចម្លើយ។ ម្យ៉ាងវិញទៀត ការទាមទារនេះ ស្ថិតនៅក្នុងកម្រិតមួយដែលច្បាប់អនុញ្ញាត និងប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតលេខ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ ត្រង់សេចក្តីសម្រេច ប្រការ១ ចែងថា៖ អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិតជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឱ្យលើសពី១៨% (ដប់ប្រាំបី) ភាគរយ ក្នុង០១ (មួយ) ឆ្នាំ ។ ដូចនេះ គប្បីតុលាការសម្រេចតាមការទាមទាររបស់



Scanned with CamScanner

ដើមចោទស្របតាមមាត្រា៤៨៥ នៃក្រមរដ្ឋប្បវេណី, មាត្រា១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រកាសលេខ១២៨ កយ.ប្រក III ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌។

យល់ឃើញថា ដើមចោទទាមទារឲ្យចុងចម្លើយបង់ប្រាក់ពិន័យលើចំនួនយឺតយ៉ាវហួសកំណត់សងចំនួន១២២.៨៣ (មួយរយម្ភៃពីរដុល្លារអាមេរិក និងហាសិបបីសេន)។ ឃើញថា ការទាមទារនេះ ភាគីចុងចម្លើយបានបដិសេធមិនទទួលស្គាល់ ហើយនៅក្នុងកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ និងលិខិតផ្តល់ឥណទាន ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ រវាងភាគីដើមចោទ និងចុងចម្លើយក៏មិនបានកំណត់ដែរ គប្បីតុលាការច្រានចោលការទាមទារនេះរបស់ដើមចោទ។

យល់ឃើញថា ដើមចោទទាមទារឲ្យចុងចម្លើយបង់កម្រៃផ្សេងៗដែលត្រូវបង់ចំនួន ៨,៨២៦.៨៥ (ប្រាំបីពាន់ប្រាំបីរយម្ភៃប្រាំមួយដុល្លារអាមេរិក និងប៉ែតសិបប្រាំសេន)។ ត្រង់ចំណុចនេះ បើទោះបីជាភាគីចុងចម្លើយបានបដិសេធកាលពីនៅក្នុងនីតិវិធីរបស់តុលាការក៏ដោយ ក៏ចុងចម្លើយធ្លាប់បានបង្ហាញឆន្ទៈព្រមព្រៀងដូចមាននៅក្នុងលិខិតផ្តល់ឥណទាន ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩។ ហេតុនេះ គប្បីតុលាការសម្រេចតាមការស្នើសុំរបស់ដើមចោទ។

យល់ឃើញថា ដើមចោទទាមទារឲ្យចុងចម្លើយបង់ការប្រាក់ហួសកំរិតចំនួន២៧.៥០% (ម្ភៃប្រាំពីរក្បៀសហាសិបភាគរយ) ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលហួសកំរិតគិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួន លើឥណទានសម្រាប់ទិញឬសាងសង់ផ្ទះ និងឥណទានសម្រាប់ប្រើប្រាស់ក្នុងផ្ទះ។ ឃើញថា ការទាមទារនេះ ចុងបានបដិសេធមិនទទួលស្គាល់ឡើយ ហើយការទាមទារនេះ ក៏ពុំមានមូលដ្ឋានតាមផ្លូវច្បាប់ដែលតុលាការត្រូវសម្រេចតាមការទាមទារដែរ។ ហេតុនេះ គប្បីតុលាការច្រានចោលការទាមទាររបស់ដើមចោទ។

យល់ឃើញថា ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ និងលិខិតផ្តល់ឥណទាន ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ រវាងភាគីដើមចោទ និងចុងចម្លើយ បានបញ្ជាក់ថា ភាគីចុងចម្លើយឯកភាព និងព្រមបង់ការប្រាក់ពិន័យទៅអោយដើមចោទ។ ហើយដើមចោទបានទាមទារឲ្យចុងចម្លើយបង់ការប្រាក់ពិន័យចំនួន២៧.៥០% (ម្ភៃប្រាំពីរក្បៀសហាសិបភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមគិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងប្រាក់គ្រប់ចំនួន ចំពោះឥណទាន



Scanned with CamScanner

សម្រាប់ទិញ ឬសាងសង់ផ្ទះ។ ឃើញថា ការដែលដើមចោទប្ដឹងទាមទារនេះ គឺលើសពីច្បាប់បានកំណត់ ដូចមាននៅក្នុងប្រកាសស្ដីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ ដែលកំណត់មិនឲ្យលើសពីចំនួន១,៥ (មួយក្បៀសប្រាំ) ដង នៃអត្រាការប្រាក់ដែលបានកំណត់។ ចំណុចនេះ តុលាការគប្បីពិនិត្យ និងសម្រេចតាមច្បាប់។

យល់ឃើញថា ដើមចោទទាមទារមកតុលាការឲ្យបង្គាប់ឲ្យចុងចម្លើយបង់សងការប្រាក់ចំនួន៣២៥.៣៣ (បីរយសែសិបប្រាំបួនដុល្លារអាមេរិក និងសាមសិបបីសេន) គិតចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ និងការប្រាក់ចំនួន៧.៥% (ប្រាំពីរក្បៀសប្រាំភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងប្រាក់គ្រប់ចំនួន ចំពោះឥណទានសម្រាប់ប្រើប្រាស់ក្នុងផ្ទះ។ ឃើញថា ការដែលដើមចោទទាមទារនេះ គឺស្របតាមឆន្ទៈរបស់ចុងចម្លើយដែលមាននៅក្នុងលិខិតផ្ដល់ឥណទានជូនចំពោះលោកស្រី [redacted] ណារ៉ុំ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ និងកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី០៩ ខែតុលា ឆ្នា២០១៩ ដែលធ្វើឡើងរវាងដើមចោទ និងចុងចម្លើយ។ ម្យ៉ាងវិញទៀត ការទាមទារនេះ ស្ថិតនៅក្នុងកម្រិតមួយដែលច្បាប់អនុញ្ញាត និងប្រកាសស្ដីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតលេខ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ ត្រង់សេចក្ដីសម្រេច ប្រការ១ ចែងថា៖ អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិតជាអាទិ៍) នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពី១៨% (ដប់ប្រាំបី) ភាគរយ ក្នុង០១ (មួយ) ឆ្នាំ ។ ដូចនេះ គប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទស្របតាមមាត្រា៥៨៥ នៃក្រមរដ្ឋប្បវេណី, មាត្រា១៧ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រកាសលេខ១២៨ កយ.ប្រក /// ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌។

យល់ឃើញថា ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ និងលិខិតផ្ដល់ឥណទាន ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ រវាងភាគីដើមចោទ និងចុងចម្លើយ បានបញ្ជាក់ថា ភាគីចុងចម្លើយឯកភាព និងព្រមបង់ការប្រាក់ពិន័យទៅអោយដើមចោទ។ ហើយដើមចោទបានទាមទារឲ្យចុងចម្លើយបង់ការ



Scanned with CamScanner

ប្រាក់ពិន័យចំនួន២៧.៥០% (ម្ភៃប្រាំពីរក្បៀសហាសិបភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើម គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងប្រាក់គ្រប់ចំនួន ចំពោះឥណទានសម្រាប់ប្រើប្រាស់ក្នុងផ្ទះ។ ឃើញថា ការដែលដើមចោទប្ដឹងទាមទារនេះ គឺលើសពីច្បាប់បានកំណត់ ដូចមាននៅក្នុងប្រកាសស្ដីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ ដែលកំណត់មិនឲ្យលើសពីចំនួន១,៥ (មួយក្បៀសប្រាំ) ដង នៃអត្រាការប្រាក់ដែលបានកំណត់។ ចំណុចនេះ តុលាការគប្បីពិនិត្យ និងសម្រេចតាមច្បាប់។

យល់ឃើញថា ដើមចោទស្នើសុំឲ្យតុលាការបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ (ហ៊ីប៉ូតែក) របស់ដើមចោទចំពោះអចលនវត្ថុដែលជាកម្មសិទ្ធិរបស់ចុងចម្លើយលើប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០០៧០៤៩ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៧ ចេញដោយប្រធានប្រធាននាយកដ្ឋានសុរិយោដីខេត្តកណ្ដាល និងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១២០១០៤០១-០២៣៥ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៧ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ។ ឃើញថា តាមរយៈសេចក្ដីថ្លែងការណ៍របស់ភាគីដើមចោទ, កិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ និងលិខិតផ្ដល់ឥណទាន ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៩ រវាងដើមចោទ និងចុងចម្លើយ អាចបញ្ជាក់បានថា អចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០០៧០៤៩ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៧ ចេញដោយប្រធានប្រធាននាយកដ្ឋានសុរិយោដីខេត្តកណ្ដាល និងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១២០១០៤០១-០២៣៥ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៧ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ ពិតជាបានបង្កើតហ៊ីប៉ូតែក និងចុះបញ្ជីហ៊ីប៉ូតែកត្រឹមត្រូវ ដើម្បីធានាបំណុលខាងលើរបស់ចុងចម្លើយប្រាកដមែន។ ហេតុនេះ គប្បីតុលាការពិនិត្យអំពីភាពត្រឹមត្រូវស្រប តាមល័ក្ខខណ្ឌនៃមាត្រា៨២៣,៨២៤ នៃក្រមរដ្ឋប្បវេណី។

យល់ឃើញថា ដើមចោទទាមទារការចំណាយលើសេវាកម្មផ្លូវច្បាប់មេធាវីចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ពីភាគីចុងចម្លើយ ឃើញថា នៅក្នុងរឿងនេះ ដើមចោទ



Scanned with CamScanner

ពិតជាបានពីងពាក់លោកមេធាវី [redacted], លោក [redacted], លោក [redacted] និងលោក [redacted] ឲ្យធ្វើជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទពិតមែន គប្បីតុលាការសម្រេចតាមច្បាប់។

យល់ឃើញថា ដើមចោទសុំឲ្យតុលាការប្រកាសថាសាលក្រមនេះមានអានុភាពអនុវត្តបណ្ដោះអាសន្នលើប្រាក់ដើម ឃើញថា ការស្នើសុំនេះ តុលាការនឹងពិនិត្យអំពីភាពត្រឹមត្រូវស្របតាមល័ក្ខខណ្ឌនៃមាត្រា១៩៦ (ការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៣.ប្រាក់ប្រដាប់ក្ដីគប្បីអនុវត្តតាមមាត្រា៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ហេតុដូច្នេះ តុលាការ ធ្វើការវិនិច្ឆ័យដូចខាងក្រោម៖

**សេចក្ដីសម្រេចបញ្ចប់**

១.បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ដែលជំពាក់មកឱ្យដើមចោទ (ឥណទានសំរាប់ទិញ ឬសាងសង់ផ្ទះ) ដូចខាងក្រោម៖

១.១.ប្រាក់ដើមដែលនៅជំពាក់ចំនួន២៧៥,៩៩៥.១៤ (ម្ភៃប្រាំពីរម៉ឺនប្រាំពាន់ប្រាំបួនរយកៅសិបប្រាំដុល្លារអាមេរិក និងដប់បួនសេន)។

១.២.ការប្រាក់ចំនួន១៧,២២១.១៣ (មួយម៉ឺនប្រាំពីរពាន់ពីររយម្ភៃមួយដុល្លារអាមេរិក និងដប់បីសេន) គិតចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣។

១.៣.ប្រានចោលការទាមទារលើប្រាក់ពិន័យត្រូវបង់លើចំនួនយឺតយាវហួសកំណត់សងចំនួន១២២.៥៣ (មួយរយម្ភៃពីរដុល្លារអាមេរិក និងហាសិបបីសេន)។

១.៤.កម្រៃផ្សេងៗត្រូវបង់ចំនួន៨,៨២៦.៨៥ (ប្រាំបីពាន់ប្រាំបីរយម្ភៃប្រាំមួយដុល្លារអាមេរិក និងប៉ែតសិបប្រាំសេន)។

១.៥.ការប្រាក់ចំនួន៧.៥% (ប្រាំពីរក្បៀសហាសិបភាគរយ) ក្នុង១ឆ្នាំ លើប្រាក់ដើមដែលនៅជំពាក់ គិតពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣។

១.៦.ប្រានចោលការទាមទារការប្រាក់ហួសកំរិតចំនួន២៧% (ម្ភៃប្រាំពីរភាគរយ) ក្នុង១ឆ្នាំ លើចំនួនទឹកប្រាក់ដែលប្រើហួសកំរិត គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួន។



Scanned with CamScanner

១.៧.ការប្រាក់ពិន័យចំនួន២៧% (ម្ភៃប្រាំពីរភាគរយ) ក្នុង១ឆ្នាំ លើលើប្រាក់ដើម គិតចាប់ពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងប្រាក់គ្រប់ចំនួន។

២.បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ដែលជំពាក់មកឲ្យដើមចោទ (ឥណទានសម្រាប់ប្រើប្រាស់ក្នុងផ្ទះ) ដូចខាងក្រោម៖

២.១.ប្រាក់ដើមដែលនៅជំពាក់ចំនួន៥៣,៦៨៦.៧៥ (ប្រាំម៉ឺនបីពាន់ប្រាំមួយរយប៉ែតសិបប្រាំមួយដុល្លារអាមេរិក និងចិតសិបប្រាំសេន)។

២.២.ការប្រាក់ចំនួន៣២៩.៣៣ (បីរយសែសិបប្រាំបួនដុល្លារអាមេរិក និងសាមសិបបីសេន) គិតចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣។

២.៣.ការប្រាក់ចំនួន៧.៥០% (ប្រាំពីរក្បៀសហាសិបភាគរយ) ក្នុង១ (មួយ) ឆ្នាំ លើប្រាក់ដើមដែលនៅជំពាក់ គិតពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣។

២.៤.ប្រានចោលការទាមទារការប្រាក់ហួសកំរិតចំនួន២៧% (ម្ភៃប្រាំពីរភាគរយ) ក្នុង១ (មួយ) ឆ្នាំ លើចំនួនទឹកប្រាក់ដែលប្រើហួសកំរិត គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួន។

២.៥.ការប្រាក់ពិន័យចំនួន២៧% (ម្ភៃប្រាំពីរភាគរយ) លើប្រាក់ដើម គិតចាប់ពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួន។

៣.បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ (ហ៊ីប៉ូតែក) របស់ដើមចោទចំពោះអចលនវត្ថុដែលជាកម្មសិទ្ធិរបស់ចុងចម្លើយ លើប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០០៧០៤៩ ចុះថ្ងៃទី២៤.១២.១៩៩៧ ចេញដោយប្រធាននាយកដ្ឋានសុរិយោដីខេត្តកណ្ដាល និងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ១២០១០៤០១-០២៣៥ ចុះថ្ងៃទី២៧.០២.២០០៧ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ។

៤.បង្គាប់ឱ្យចុងចម្លើយសងសេវាកម្មផ្លូវច្បាប់សម្រាប់មេធាវីចំនួន ៨,០០០,០០០ (ប្រាំបីលាន) រៀល ឲ្យមកដើមចោទ។ ការទាមទារលើសពីនេះត្រូវប្រានចោល។

៥.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

៦.សាលក្រមអាចអនុវត្តជាបណ្ដោះអាសន្នបានត្រង់ចំណុច១.១ និង២.១ នៃសេចក្ដីសម្រេច។

សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ និង ប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ ។

ទុកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់។

ថ្ងៃសុក្រ ១១កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស២៥៦៧

ខេត្តកណ្តាល, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤

**ចៅក្រម**

ហត្ថលេខា និងត្រា ៖ [redacted]

---

**បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ ១១កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស២៥៦៧

ខេត្តកណ្តាល, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner